ការលះបង់សិទ្ធិរបស់ចុងចោទ	លេខសំណុំរឿង	តុលាការរដ្ឋម៉ាស្សាជូសេស្ត៏ នាយកដ្ឋានសាលាដំបូងថ្នាក់ខ្ពស់
ឈ្មោះសំណុំរឿង : VS.		ក្រឡាបញ្ជីតុលាការ ខោនធី
OFFICIAL TRIAL COURT TRANSLATION COMMITTEE សំរាប់ជាឯកសារយោងតែប៉ុណ្ណោះ, កុំបញ្ជូនទៅតុលាការ 11/22/2022		ឈ្មោះតុលាការ & អាស័យដ្ឋាន

ខ្ញុំបានពិភាក្សាករណីខាងលើជាមួយមេធាវីរបស់ខ្ញុំ។ ខ្ញុំយល់ថា តាមរយៈការផ្តល់ចម្លើយថាមានពិរុទ្ធ ខ្ញុំនឹងបោះបង់ចោលសិទ្ធិតាមរដ្ឋធម្មនុញ្ញ និងច្បាប់ដូចខាងក្រោម៖
សិទ្ធិទទួលការជំនុំជំរះដោយគណៈវិនិច្ឆ័យ ឬដោយចៅក្រម; ប្រឈមមុខ នឹងស្មរខ្មែងសាក្សី; ដើម្បីហៅសាក្សីផ្តល់របស់ខ្ញុំ និងបង្ហាញភស្តុតាងក្នុងការការពារក្តីរបស់ខ្ញុំ;
សិទ្ធិមិនចាំបាច់និយាយស្តី និងអះអាងឯកសិទ្ធិរបស់ខ្ញុំប្រឆាំងនឹងការឆ្លើយដាក់ខ្លួនឯង; សន្មតថាគ្មានទោស
រហូតទាល់តែមានការបញ្ជាក់អំពីកំហុសលើសពីការសង្ស័យសមហេតុផល; និងសិទ្ធិដាក់ញត្តិភាំណាមួយនៅក្នុងករណីរបស់ខ្ញុំ។ ខ្ញុំក៏យល់ផងដែរថា
ខ្ញុំនឹងបោះបង់សិទ្ធិប្តឹងឧទ្ធរណ៍ចំពោះសេចក្តីសម្រេចណាមួយដែលតុលាការនេះបានចេញរួចហើយ លុះត្រាតែតាមរយៈកិច្ចព្រមព្រៀងជាលាយ លក្ខណ៍អក្សរវាងខ្ញុំ
និងខាងរដ្ឋអាជ្ញា ដែលត្រូវធ្វើឡើងក្នុងតុលាការ, ខ្ញុំរក្សាសិទ្ធិដើម្បីប្តឹងឧទ្ធរណ៍នូវការសម្រេចដាក់លក់ណាមួយ ឬសេចក្តីសម្រេច ប្រសិនបើមានការបដិសេធលើ
បណ្តឹងឧទ្ធរណ៍ ដែលធ្វើឱ្យសំណុំរឿងរបស់រដ្ឋអាជ្ញាមិនមានប្រសិទ្ធិភាពលើការចោទប្រកាន់មួយ ឬច្រើនជាងមួយ។

ខ្ញុំត្រូវបានណែនាំដោយមេធាវីរបស់ខ្ញុំអំពីលក្ខណៈ និងធាតុផ្សំនៃការចោទប្រកាន់ ដែលខ្ញុំកំពុងផ្តល់ចម្លើយថាមានពិរុទ្ធ និងអំពីលក្ខណៈ
និងទំហំនៃការដាក់ទោសដែលអាចកើតមានចំពោះការចោទប្រកាន់នានា រួមទាំងការកាត់ទោសជាអតិបរមាដែលអាចកើតមាន ទោសអប្បបរមាដែលអាចអនុវត្តបាន
ផលវិបាកប្រសិនបើត្រូវបានគេដាក់ក្រោមអាជ្ញាសង្កេត និងការលើសលក្ខខណ្ឌណាមួយ ហើយនិងការដាក់ទណ្ឌកម្មផ្សេងៗ ឬបន្ថែមទៀតសម្រាប់បទល្មើសជាបន្តបន្ទាប់។

[ចុចទីនេះ បើសិនជាមាន] ខ្ញុំត្រូវបានគេជំរាបឱ្យដឹងពីច្បាប់ពិរុទ្ធជនជាទម្លាប់ និងផលវិបាកនៃការផ្តល់ចម្លើយថាមានពិរុទ្ធចំពោះការចោទប្រកាន់នៅពេលនេះ។
[ចុចទីនេះ បើសិនជាមាន] ខ្ញុំត្រូវបានគេជំរាបឱ្យដឹងថា តាមការផ្តល់ចម្លើយថាមានពិរុទ្ធចំពោះការចោទប្រកាន់បច្ចុប្បន្ននេះ ខ្ញុំអាចនឹងត្រូវគេចាត់ទុក
ជាមនុស្សគ្រោះថ្នាក់ខាងផ្លូវភេទ ហើយតម្រូវឱ្យចុះឈ្មោះជាអ្នកប្រព្រឹត្តល្មើសផ្លូវភេទ។

ខ្ញុំត្រូវបានគេជំរាបឱ្យដឹងពីអនុសាសន៍ក្នុងការដាក់ទោសដែលនឹងត្រូវធ្វើឡើងខាងរដ្ឋអាជ្ញា។

ការផ្តល់ចម្លើយរបស់ខ្ញុំថាមានពិរុទ្ធ មិនមែនជាលទ្ធផលនៃការបង្ខំ ការគំរាមកំហែង ការជានា ឬការសន្យាអ្វីទេ។ ខ្ញុំបានសម្រេចចិត្តសារភាពកំហុសដោយស្ម័គ្រចិត្ត
តាមឆន្ទៈ និងដោយសេរី ជាជាងតាមការដឹកច្រមុះ ឬដោយសារការណែនាំពីអ្នកណាម្នាក់ឡើយ។

ខ្ញុំពេញចិត្តដែលមេធាវីការពារក្តីរបស់ខ្ញុំបានធ្វើជាតំណាងឱ្យខ្ញុំប្រកបដោយប្រសិទ្ធិភាព និងមានសមត្ថភាពពេញលេញ។ ខ្ញុំមានពេលគ្រប់គ្រាន់ដើម្បីនិយាយជាមួយគាត់
ទាក់ទងនឹងការការពារណាដែលអាចប្រើប្រាស់បានចំពោះការចោទប្រកាន់នានាខាងលើ ហើយគាត់បានពន្យល់ពីផលវិបាកនៃការផ្តល់ចម្លើយថាមានពិរុទ្ធរបស់ខ្ញុំ
ហើយនិងការលះបង់សិទ្ធិតាមរដ្ឋធម្មនុញ្ញ ឬច្បាប់ណាមួយ។

ឥឡូវនេះ ខ្ញុំមិនស្ថិតក្រោមឥទ្ធិពលនៃគ្រឿងញៀន ឱសថ ស្រា ឬគ្រឿងស្រវឹង ឬថ្នាំរំងាប់អារម្មណ៍ផ្សេងទៀត
ដែលនឹងធ្វើឱ្យប៉ះពាល់ដល់សមត្ថភាពរបស់ខ្ញុំក្នុងការយល់ដឹងពេញលេញអំពីសិទ្ធិរដ្ឋធម្មនុញ្ញ និងច្បាប់ដែលខ្ញុំកំពុងលះបង់ នៅពេលដែលខ្ញុំផ្តល់ចម្លើយថាមានពិរុទ្ធ។

ខ្ញុំដឹងថា បើសិនជាខ្ញុំមិនមែនជាពលរដ្ឋនៃសហរដ្ឋអាមេរិកទេ ការផ្តន្ទាទោសនៅក្នុងករណីខាងលើអាចបណ្តាលឱ្យមានការនិរទេសខ្ញុំ
ការបដិសេធមិនឱ្យចូលសហរដ្ឋអាមេរិក ឬការបដិសេធមិនឱ្យចូលសញ្ជាតិ។

កាលបរិច្ឆេត សរសេរឈ្មោះរបស់ចុងចោទ

ហត្ថលេខារបស់ចុងចោទ _____

<u>ការយល់ព្រមរបស់មេធាវីការពារក្តី</u>
ខ្ញុំបានពិភាក្សាអំពីអង្គហេតុក្នុងករណីនេះ និងអនុសាសន៍ការឆ្លើយទទួលជាមួយក្មួនក្តីរបស់ខ្ញុំយ៉ាងលម្អិត
ហើយខ្ញុំបានណែនាំដល់ចុងចោទអំពីបញ្ហាទាំងអស់នៅក្នុងវិសាលភាពនៃវិធានៃនីតិវិធីព្រហ្មទណ្ឌនៃរដ្ឋម៉ាស្សាជូសេស្ត៏ លេខ 12
ដែលពាក់ព័ន្ធនឹងការឆ្លើយទទួលរបស់ចុងចោទ រួមទាំងការជូនដំណឹងដល់ចុងចោទជាដែរពីសិទ្ធិរដ្ឋធម្មនុញ្ញ និងច្បាប់របស់គាត់, មូលដ្ឋានជាក់ស្តែងសម្រាប់
និងលក្ខណៈ និងធាតុផ្សំនៃបទល្មើស ដែលការប្តឹងផ្តល់មានទោសនឹងត្រូវបានដេញថ្លៃ ការការពារដែលអាចកើតមាន និងផលវិបាកនៃការសារភាពកំហុស។

បន្ទាប់ពីការពន្យល់ខាងលើដល់ចុងចោទរួចមក ខ្ញុំពេញចិត្តដែលចុងចោទបានយល់ពីការពន្យល់របស់ខ្ញុំ និងផលវិបាកនៃការផ្តល់ចម្លើយថាមានពិរុទ្ធរបស់គាត់។
ជាងនេះទៅទៀត ខ្ញុំពេញចិត្តដែចុងចោទមិនស្ថិតក្រោមឥទ្ធិពលនៃគ្រឿងញៀន ឱសថ ស្រា ឬសារធាតុពុលផ្សេងទៀត
ដែលអាចប៉ះពាល់ដល់សមត្ថភាពរបស់ចុងចោទក្នុងការយល់ដឹងពេញលេញអំពីរដ្ឋធម្មនុញ្ញ ច្បាប់
និង/ឬសិទ្ធិផ្សេងទៀតដែលចុងចោទនឹងលះបង់ដោយការផ្តល់ចម្លើយដោយឥតលក្ខខណ្ឌថាមានពិរុទ្ធចំពោះការចោទប្រកាន់ខាងលើ។

ខ្ញុំសូមដំរាបទៅតុលាការថា ចុងចោទបានចុះហត្ថលេខាលើឯកសារនេះដោយមានវត្តមានខ្ញុំផ្ទាល់ ដោយសេរី តាមឆន្ទៈ និងស្ម័គ្រចិត្ត។
កាលបរិច្ឆេត _____ មេធាវីរបស់ចុងចោទ _____
លេខ BBO _____